## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

មាត្រា ១៦ .- ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី តាមសំណូមពររបស់អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

មាត្រា ១៧.-បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៨ .- ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័ន និង សមាជិកទាំងអស់ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

ហត្ថលេខា

សុខ អាន

***

## អនុក្រឹត្យ លេខ ៥៣ អនក្រ.បក
## ស្ដីពីការធ្វើវិសោធនកម្ម លើអនុក្រឹត្យ ស្ដីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃ ព្រះរាជាណាចក្រកម្ពុជា លេខ ៨៨ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

* * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

-យោងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានប្រកាសចំពោះមុខរដ្ឋសភា នៅថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

-តាមការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ កាលពីថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ១៩៩៩

**សំរេច**

មាត្រា ១ .– មាត្រា២៣ (ស្តីពីកាតព្វកិច្ចរបស់សហគ្រាសវិនិយោគ) -នៃអនុក្រឹត្យ លេខ ៨៨ អនក្រ បក ស្តីពីការអនុវត្តច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែប្រែដូចខាងក្រោមនេះ :

-ចំណុច ២៣-ញ: < ការផ្តល់ព័ត៌មានផ្សេងៗទៀត > : សហគ្រាសវិនិយោគ ត្រូវផ្តល់ក្នុងមួយត្រីមាសម្តង ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករ >

-ចំណុច ២៣-ឍ ផ្នែក ខ: < បញ្ជីរាយលំអិត ស្តីពីការនាំចូលជាក់ស្តែងនូវទំនិញ ដែលប្រើអោយផលិតកម្ម និងបញ្ជីរាយលំអិត ស្តីពីការនាំចេញនូវផលិតផលរបស់គំរោង វិនិយោគ ។

មាត្រា ២.– ឧបសម្ព័ន្ធទី១ - នៃអនុក្រឹត្យ លេខ ៨៨ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែប្រែនៅត្រង់ តារាង ក និង តារាង ខ ដូចតទៅ :

ឧបសម្ព័ន្ធទី១ តារាង ក (បញ្ជីនៃវិស័យសំរាប់វិនិយោគដែលត្រូវទទួលការលើកទឹកចិត្ត) ត្រូវកែប្រែនៅ :

ចំណុច ៦ (ការផលិតសំលៀកបំពាក់ និងវាយនភ័ណ្ឌផ្សេងៗទៀត) : ដើមទុនវិនិយោគសមមូល ត្រូវបានកែប្រែទៅជា ១.០០០.០០០ ដុល្លារ (មួយលានដុល្លារអាមេរិក) ឡើងទៅ

ចំណុច ៧ (ការផលិតគ្រឿងសង្ហារឹម និងគ្រឿងសំរាប់តាំងភ្ជាប់) ដើមទុនវិនិយោគសមមូល ត្រូវបានកែប្រែទៅជា ១.០០០.០០០ ដុល្លារ (មួយលានដុល្លារអាមេរិក) ឡើងទៅ

ចំណុច ៩ ( ការផលិតធាតុគីមី និងផលិតផលរួមសម្ព័ន្ធ ) ដើមទុនវិនិយោគសមមូល ត្រូវបានកែប្រែទៅជា ១.០០០.០០០ ដុល្លារ (មួយលានដុល្លារអាមេរិក) ឡើងទៅ

ចំណុច១២ ( ការផលិតផលធ្វើពីលោហៈគ្រប់ប្រភេទ ) ដើមទុនវិនិយោគសមមូល ត្រូវបានកែប្រែទៅជា ១.០០០.០០០ ដុល្លារ (មួយលានដុល្លារអាមេរិក) ឡើងទៅ

ចំណុច ១៥ ( ការសាងសង់ស្ពានថ្នល់ ) ត្រូវបានប្តូរ និងបន្ថែមទៅជាការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត រួមទាំងការផលិតថាមពលអគ្គិសនី និងការផលិតទឹកស្អាត ។

ចំណុច ១៦ ( អាជីវកម្មរ៉ែ លោហធាតុ ត្បូងថ្ម ប្រេង និង ឧស្ម័ន ) ត្រូវបានលុបចោល

ចំណុច ១៧ ( ការផលិតគ្រឿងម៉ាស៊ីន និងសំភារៈបរិក្ខារ ឧស្សាហកម្ម ) ដើមទុនវិនិយោគ ត្រូវបានកែប្រែទៅជា ១.០០០.០០០ ដុល្លារ (មួយលានដុល្លារអាមេរិក) ឡើងទៅ

ចំណុច ១៨ ( ការផលិតឧបករណ៍ប្រើប្រាស់ ) ត្រូវបានលុបចោល

ឧបសម្ព័ន្ធទី១ ខាង ខ ( បញ្ជីនៃវិស័យវិនិយោគ ដែលមិនត្រូវបានទទួលការលើកទឹកចិត្ត ) ត្រូវបាន បន្ថែមចំណុចពីរថ្មីទៀត គឺចំណុចទី៩ <សេវាទូរគមនាគមន៍> និង ចំណុចទី១០ <អាជីវកម្មរ៉ែ ធនធានធម្មជាតិ > លើកលែងតែការរុករកលើប្រេង និង ឧស្ម័ន ។

មាត្រា ៣ : ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ៨៨ អនក្រ បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែប្រែនៅក្នុង ខាង ក និង ខាង ខ ដូចតទៅ :

ខាង ក បន្ទាប់ពីវាក្យខ័ណ្ឌចុងក្រោយ ត្រូវបានបន្ថែមឃ្លា <ប្រភេទវិនិយោគ ដែលមានចែងនៅក្នុង ចំណុច១-៥ មិនរាប់បញ្ចូលនូវអាជីវកម្មរ៉ែធនធានធម្មជាតិទេ លើកលែងតែការរុករកប្រេង និង ឧស្ម័ន >

ខាង ខ ចំណុចទី៥ ត្រូវបានកែប្រែដូចតទៅ <វត្ថុធាតុដើម និងផលិតផលពាក់កណ្តាលសំរេច ប្រើប្រាស់ផ្ទាល់ក្នុងដំណើរការផលិតកម្ម ក្រៅពីប្រេងឥន្ធនៈគ្រាប់ប្រោះ>

មាត្រា ៤ .- រាល់បទបញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

***